រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

045KH01A-01

របៀបធ្វើអោយមានការសំរេចចិត្ត ព្រមព្រៀងគ្នា នៅក្នុងអង្គប្រជុំ ខាងផ្នែកគ្រប់គ្រង



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៤៥

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ទូលសូមអោយព្រះជាម្ចាស់ជួយអ្នក តាមរយៈការសិក្សានេះ ដើម្បីអោយសមាជិក និង គ្រួគង្វាលទាំងអស់របស់ក្រុមជំនុំអ្នក អាចមានការសំរេចចិត្តព្រមព្រៀងគ្នា ។

ពេលដែលអ្នកអានក្ងនសៀវភៅនេះ សូមនឹកចាំថា មានុស្សមានវប្បធម៌ផ្សេងៗ ធ្វើអោយមានការសំរេចចិត្តព្រមព្រៀងគ្នា នៅក្នុងអង្គប្រជុំខាងផ្នែកគ្រប់គ្រង តាមរបៀបផ្សេងៗ ។ ក្ងនសៀវភៅនេះមានដាក់ជូនវិធីផ្សេងៗ ប៉ុន្តែ អ្នកចាំបាច់ត្រូវពិចារណាតម្រូវវិធីទាំងនេះ អោយត្រូវនឹងវប្បធម៌របស់អ្នក ។

ព្រះយេស៊ូគ្រីស្តមានព្រះបន្ទូលថា÷ *«បើអ្នកស្រឡាញ់គ្នាទៅវិញទៅមក មនុស្សទាំងអស់មុខជាដឹងថា អ្នករាល់គ្នាពិតជាសាវ័ករបស់ខ្ញុំមែន »* ។

(យ៉ូហាន ១៣:៣៥)

គេអាចមើលដឹងថា មនុស្សមួយក្រុមជាក្រុមជំនុំរបស់ព្រះគ្រីស្តបានដោយសារសមាជិកនៃក្រុមនោះមានការស្រុះស្រួលគ្នាល្អ ។ យើងតែងមានមតិផ្សេងៗគ្នា ក៏ប៉ុន្តែ យើងអាចស្រុះស្រួលគ្នាតាមរយៈការប្រជុំដែលមានការដឹកនាំល្អត្រឹមត្រូវ ។

កិច្ចការដែលត្រូវអនុវត្ត

បង្រៀនពួកអ្នកដឹកនាំ និង ក្រុមជំនុំរបស់អ្នកអោយចេះសំរេចចិត្តព្រមព្រៀងគ្នា ដោយ :

- ខិតខំធ្វើអោយមានការព្រមព្រៀងជាងកច្ឆន្ទ ។
- ពិនិត្យមើលមតិផ្សេងៗ ដោយចំហ ។
- អស់អ្នកដែលជាប់ទាក់ទងនឹងបញ្ហាណាមួយ ត្រូវចូលរួមដោះស្រាយទាំងអស់គ្នា មិនមែននិយាយដើមគេ ពីក្រោយខ្នងទេ ។
- ផ្តល់សិទ្ធិអោយគេអាចនិយាយបានគ្រប់គ្នា (ប៉ុន្តែ មិនមែនដើម្បីរះគន់បុគ្គលណាម្នាក់ ដោយមិនបាននិយាយជាមួយអ្នកនោះផ្ទាល់ជាមុនសិននោះទេ) ។
- នៅស្ងៀម ពេលអ្នកដទៃនិយាយ (និយាយម្នាក់ម្តង) ។
- ទូលសូមអោយព្រះជាម្ចាស់ដឹកនាំអ្នក តាមរយៈព្រះបន្ទូលព្រះអង្គ ។
- ទូលសូម និង ធ្វើតាមការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅគ្រប់ពេលប្រជុំ ។ ត្រូវសុខចិត្តលះបង់មតិខ្លួនផ្ទាល់ដើម្បីធ្វើឱ្យមានការសំរេចព្រមព្រៀងគ្នាជាមួយគ្នាទាំងអស់ ។

© Project WorldReach © SEAN



នៅពេលមានមតិផ្សេងៗគ្នា យើងមិនអាចបង្ខំមនុស្សម្នាក់ៗក្នុងក្រុមឱ្យមានសភាពដូចគ្នាបានទេ ។ ឧបមាថា បើសិនជាមានគ្រីស្តជនម្នាក់អធិស្ឋាននៅពេលព្រឹក ហើយម្នាក់ទៀតអធិស្ឋាននៅពេលយប់ យើងមិនត្រូវរាប់ថា គេគ្មានឯកភាពទេ ។ គេគ្រាន់តែធ្វើតាមរបៀបផ្សេងគ្នា ស្របទៅតាមស្ថានភាពរបស់គេផ្ទាល់ប៉ុណ្ណោះ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អ្នកទាំងពីរនោះមានឯកភាពក្នុងអង្គព្រះគ្រីស្តដែរ ។ ឯកភាពក្នុងព្រះគ្រីស្ត មិនមែនជាការដូចគ្នាគ្រប់យ៉ាងទេ ។ សំបុត្ររបស់លោកប៉ូលបង្រៀនយើងថា យើងមានឯកភាពតែមួយ គឺថាមានតម្លៃដូចគ្នានៅចំពោះព្រះភក្ត្រព្រះជាម្ចាស់ (ឯកភាពខាងព្រលឹងវិញ្ញាណក្នុងព្រះគ្រីស្ត) ។ យើងជាក្រុមជំនុំតែមួយរបស់ព្រះគ្រីស្តពិតមែន តែយើងមានសេរីភាពបំរើព្រះជាម្ចាស់ តាមរយៈអំណោយទាន និង តាមរបៀបផ្សេងៗគ្នា (រ៉ូម ១២:៣-១៦, ១ កូរិនថូស ជំពូក ១២-១៣, អេភេសូ ៤:១-១៦) ។

៩- ក្រោយពីបានពិភាក្សាដោយសេរីមក លោកយ៉ាកុបបានស្នើជូនដំណោះស្រាយមួយ ដែលស្របទៅតាម :

☐ ព្រះគម្ពីរ ។

☐ គំនិតរបស់គាត់ផ្ទាល់ ។

១០- គំនិតរបស់លោកយ៉ាកុប យកតាមព្រះបន្ទូលព្រះជាម្ចាស់ ។ ពួកសាវ័កទទួលធ្វើតាមគំនិតនេះ ដោយសារ :

☐ ព្រះវិញ្ញាណដ៏វិសុទ្ធ ។

☐ ក្រិត្យច្បាប់តឹងរឹង ។

១១- ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នាំអោយ :

☐ គ្រប់គ្នាសំរេចចិត្តព្រមព្រៀងគ្នា ។

☐ មនុស្សតែមួយចំនួន សំរេចចិត្តព្រមព្រៀងគ្នា ។

ទោះជាយើងមានមតិផ្សេងគ្នាក៏ដោយ ក៏យើងគោរពគ្នា និង មានទំនាក់ទំនងល្អរវាងគ្នា និង គ្នាជានិច្ច ។ កិច្ចការ ជំពូក ១៥ បង្រៀនយើងអំពីរបៀបដ៏ល្អ ដែលក្រុមជំនុំនៅក្រុងយេរូសាឡឹម ប្រើ ពេលធ្វើសេចក្តីសំរេចរួមជាមួយគ្នា ។ នៅក្នុងនោះ យើងអាចឃើញខ្នាតគំរូប្រាំពីរយ៉ាង សំរាប់ណែនាំអោយមនុស្សចេះធ្វើការសំរេច ដោយព្រមព្រៀងគ្នា ។ យើងនឹងពិនិត្យមើលការប្រជុំរបស់ក្រុមជំនុំនៅក្រុងយេរូសាឡឹម ដើម្បីរៀនអំពីក្បួនច្បាប់ទាំងប្រាំពីរនោះ ។

ច្បាប់ ទី ១

ពួកគេដោះស្រាយការខ្វែងមតិគ្នា ដោយចំហ

សូមអាន កិច្ចការ ១៥:១-៥ ។

គោលគំនិតសំខាន់ៗដែលដកស្រង់ពីខគម្ពីរទាំងនេះ :

- បញ្ហានេះធ្ងន់ធ្ងរណាស់ ព្រោះទាក់ទងនឹងឫសគល់នៃជំនឿ ។
- នៅក្នុងក្រុមជំនុំដំបូងរបស់ពួកសាវក មានការខ្វែងមតិគ្នា ។ នៅក្នុងក្រុមជំនុំណា ក៏តែងតែមានការខ្វែងមតិគ្នាដែរ ។
- យើងអាចដោះស្រាយការខ្វែងគំនិតគ្នា ដោយធ្វើតាមរបៀបរបស់ពួកសាវកដែរ ។

៥- យើងអាចឃើញគំរូដ៏ល្អ អំពីរបៀបធ្វើឱ្យមានការសំរេចចិត្តព្រមព្រៀងគ្នា នៅក្នុង កិច្ចការ ១៥ នៅក្នុងក្រុមជំនុំនៅ :

- ☐ ទីក្រុងយេរូសាឡឹម ។
- ☐ ទីក្រុងម៉ិកស៊ីកូ (Mexico City) ។
- ☐ ទីក្រុងរ៉ូម ។

៦- នៅក្រុងយេរូសាឡឹម មានការមិនចុះសំរុងគ្នា :

- ☐ ខ្លាំងណាស់ ។
- ☐ តិចតួច ។

៧- ទំនាស់ត្រូវបានផ្សះផ្សាវិញ តាមរយៈ :

- ☐ ការថ្វាយបង្គំ ។
- ☐ ការប្រជុំខាងផ្នែកគ្រប់គ្រង ។

៨- នៅពេលប្រជុំនេះ តើអ្នកចូលរួមធ្វើអ្វី ?

- ☐ រិះគន់ ។
- ☐ ពិភាក្សាដោយសេរី ។
- ☐ ជជែកឡូឡា ។

ការប្រឡង (សំនួរសង្ខេបមេរៀន)

១- បើគ្រីស្តជនពីរនាក់មានបញ្ហាជាមួយគ្នា ត្រូវអោយអ្នកទាំងពីរនោះ ដោះស្រាយបញ្ហាតែពីរនាក់ ។ ព្រោះអ្វី ? ។

_____

_____

២- សមាជិកម្នាក់មិនត្រូវនិយាយច្រើនដងទេ បើសិនជាសមាជិកឯទៀតមិនទាន់បាននិយាយម្តងផងនោះ ។ ព្រោះអ្វី ? ។

_____

_____

៣- ហេតុអ្វីបានជាយើងមិនត្រូវនិយាយកាត់គ្នាទៅវិញទៅមក ? ។

_____

_____

៤- តើក្នុងចំណោមវគ្គព្រះគម្ពីរទាំងពីរនេះ វគ្គព្រះគម្ពីរណាមួយដែលបង្រៀនអំពីរបៀបដឹកនាំការប្រជុំខាងផ្នែកគ្រប់គ្រង ?

☐ យ៉ូហាន ជំពូក ១៥ ។

☐ កិច្ចការ ជំពូក ១៥ ។

ជំបួង ពួកគេនិយាយដោយគោរព និង ដោយចំហអំពីមតិផ្សេងៗរបស់ពួកគេ ។ នៅក្នុងអង្គប្រជុំ ពួកគេមិននៅស្ងៀម ឬ មិនលាក់ការខ្វែងមតិគ្នាទៅវិញទៅមកឡើយ ។

ការខ្វែងមតិគ្នា ដែលពួកសាវ័កខំសម្រុះសម្រួល ជា :

☐ ការខ្វែងមតិគ្នាបន្តិចបន្តួច ។

☐ ការខ្វែងមតិគ្នាដ៏ខ្លាំងក្លា ។

(សូមរកមើលចំលើយរបស់អ្នកនៅក្នុង ខ ២) ។

ច្បាប់ ទី ២

អ្នកដែលមានការពាក់ព័ន្ធនឹងបញ្ហា ត្រូវចូលរួមដោះស្រាយបញ្ហាទាំងអស់គ្នា

សូមអាន កិច្ចការ ១៥:៦ ។

អស់អ្នកណាដែលមានការពាក់ព័ន្ធនឹងបញ្ហានោះ បានជួបជុំគ្នាដើម្បីដោះស្រាយបញ្ហា (កិច្ចការ ១៥:២២) ។



© Project WorldReach © SEAN

គោលគំនិតសំខាន់ៗដែលដកស្រង់ពីខគម្ពីរទាំងនេះ :

- បើសមាជិកពីរនាក់មានទំនាស់ជាមួយគ្នា ត្រូវអោយអ្នកទាំងពីរនោះដោះស្រាយជាមួយគ្នាទៅ មិនចាំបាច់អោយក្រុមជំនុំទាំងមូលមកចូលរួមដោះស្រាយទេ ។
- បើមានបញ្ហាក្នុងចំណោមអ្នកដឹកនាំ ត្រូវឱ្យអ្នកដឹកនាំទាំងនោះដោះស្រាយបញ្ហា (គ្រូគង្វាល និង ពួកអ្នកចាស់ទុំ) ។
- បើមានបញ្ហាដែលប៉ះពាល់ដល់ក្រុមជំនុំទាំងមូល ប្រហែលជាត្រូវដោះស្រាយបញ្ហានោះក្នុងអង្គប្រជុំ ដែលមានសមាជិកទាំងអស់ចូលរួម (ប៉ុន្តែ អ្នកដឹកនាំអាចពិភាក្សាគ្នាពីបញ្ហានោះជាមុនសិន) ។
- ពេលយើងដោះស្រាយបញ្ហានៅក្នុងអង្គប្រជុំ យើងត្រូវចៀសវាងការប្រើល្បិច ដើម្បីយកឈ្នះលើគ្នា ។ លើសពីនេះទៅទៀត ត្រូវចៀសវាងការប្រឆាំងនឹងគំនិតមនុស្សម្នាក់ និង ការជំរុញអោយគេគាំទ្រខាងយើង ។ យើងត្រូវអនុញ្ញាតិអោយអ្នកចូលរួមបញ្ចេញគំនិតយោបល់គ្រប់យ៉ាង ដោយចំហ ក្នុងបរិយាកាសគោរពគ្នាទៅវិញទៅមក ។

ក្រុមមនុស្សដែលមានវប្បធម៌ផ្សេងៗដោះស្រាយបញ្ហា ដោយរបៀបផ្សេងគ្នា ។ ឧទាហរណ៍ នៅក្នុងតំបន់មួយនៅទ្វីបអាហ្វ្រិក គេពិភាក្សាពីបញ្ហាជាមួយពួកមនុស្សសំខាន់ៗក្នុងសង្គមសិន មុននឹងធ្វើការប្រជុំខាងផ្នែកគ្រប់គ្រង ។ មនុស្សដែលនៅក្មេង សុំយោបល់ពីមនុស្សចាស់ជាង ស្ត្រីសួរយោបល់ពីបុរស ។ល។ ។ តំបន់ដែលអ្នកទទួលខុសត្រូវ អាចមានរបៀបរបបពិសេស តាមវប្បធម៌របស់ខ្លួន សំរាប់ធ្វើអោយមានការព្រមព្រៀងគ្នា នៅក្នុងអង្គប្រជុំខាងផ្នែកគ្រប់គ្រង ដែលគ្មានដាក់ជូននៅក្នុងការសិក្សានេះ ។ បើមានដូច្នេះមែន សូមកត់របៀបរបបនោះ នៅខាងក្រោមនេះ :

© Project WorldReach © SEAN

ច្បាប់ ទី ៣

អ្នកដែលចូលរួមមានសិទ្ធិបញ្ចេញយោបល់គ្រប់ៗគ្នា

សូមអាន កិច្ចការ ១៥:៧-១១ ។

សារីកពេត្រុស :

☐ និយាយតែម្នាក់ឯង នៅពេលដែលត្រូវពិភាក្សាជាមួយអ្នកឯទៀត ។

☐ រង់ចាំដល់វេនគាត់ត្រូវនិយាយ ទើបនិយាយ ។

គោលគំនិតសំខាន់ៗដែលដកស្រង់ពីខគម្ពីរទាំងនេះ :

- ពេលពិភាក្សា គ្មាននរណាម្នាក់ដណ្តើមនិយាយតែម្នាក់ឯងទេ ។
- លោកពេត្រុសមិនរិះគន់ពួកផារីស៊ីទេ តែលោកពន្យល់អំពីស្ថានភាព ដោយសេចក្តីស្រឡាញ់ ។ លោកបានលើកហេតុផល មកនិយាយយ៉ាងសមរម្យ ។



- នៅពេលប្រជុំ យើងមិនត្រូវរិះគន់គេទេ ។ នៅក្នុងករណីដែលមានទំនាស់ផ្ទាល់ខ្លួនជាមួយអ្នកណាម្នាក់ យើងត្រូវដោះស្រាយបញ្ហាជាមួយអ្នកនោះ ដោយផ្ទាល់ ។
- សមាជិកទាំងអស់មានសិទ្ធិនិយាយទាំងអស់គ្នា ។ យើងត្រូវផ្តល់ឱកាសអោយពួកគេនិយាយផង ។ បើមានអ្នកណាម្នាក់និយាយវែងពេក ឬ មិនត្រូវតាមសាច់រឿងដែលលើកយកមកពិភាក្សា អ្នកដឹកនាំអាចជួបប្រជុំតែជាមួយអ្នកនោះ តែពីរនាក់បាន ។ អ្នកដឹកនាំធ្វើដូចនេះ ដើម្បីផ្តល់ឱកាសឱ្យអ្នកនោះនិយាយ ប៉ុន្តែ មិនបង្អាក់ការងាររបស់ក្រុមទាំងមូលទេ ។



សេចក្តីសំខាន់ :

បើសិនជាមានអ្នកណាម្នាក់ធ្វើខុសមកលើអ្នក អ្នកត្រូវដោះស្រាយជាមួយអ្នកនោះសិន មុននឹងទៅប្រាប់អ្នកឯទៀត អោយជួយដោះស្រាយ (ម៉ាថាយ ១៨:១៥-១៧) ។ យើងធ្វើដូច្នេះ ដើម្បីចៀស

ច្បាប់ ទី ៧

អ្នកចូលរួមទាំងអស់គ្នាចុះចូលនឹងការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ

សូមអាន កិច្ចការ ១៥:២៨-២៩ ។

គោលគំនិតសំខាន់ៗ ដែលដកស្រង់ពីខគម្ពីរទាំងនេះ :

- នេះជាការអស្ចារ្យហើយ ដែលពួកផារីស៊ីជាអ្នកជឿបានព្រមព្រៀងដែរ ។ ទោះបីជាពួកគេរឹងយ៉ាងណាក៏ដោយ ក៏ពួកគេត្រូវតែចុះចូលតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែរ ។
- នៅក្នុងការប្រជុំរបស់យើង យើងទទួលធ្វើតាមការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបើកសំដែងតាមរយៈគ្រីស្ត-ជន និង អ្នកដឹកនាំឯទៀត ដូចក្នុងវគ្គគម្ពីរនេះដែរ ។

ព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំពួកសាវ័កតាមរយៈ :

☐ ទំនៀមទម្លាប់ ។

☐ ព្រះគម្ពីរ ។

ទីពីរ : យើងអាចព្រលែងប៉េងប៉ោងឱ្យហោះទៅលើមេឃចោលទៅ ។ នេះក៏ដូចជាក្រុមជំនុំដែរ ។ បើអ្នកដឹកនាំមិនខំដោះ-ស្រាយការខ្វែងមតិគ្នា ដោយត្រង់ៗទេ ។ ក្រុមជំនុំនោះ ក៏ប្រៀបដូចជាប៉េងប៉ោងដែលហោះទៅ គ្មានទីដៅ ដូច្នោះដែរ ។



ទីបី : យើងអាចកាន់ប៉េងប៉ោងឱ្យជាប់ រួចបន្ធូរដៃឱ្យខ្យល់ចេញបន្តិចម្តងៗ ។ នេះក៏ដូចជាក្រុមជំនុំដែរ យើងត្រូវដោះស្រាយការខ្វែងគំនិតគ្នាដោយអំណត់ ក្នុងឋានៈជាអ្នកដឹកនាំ ដែលចាស់ទុំខាងព្រលឹងវិញ្ញាណ ក្រោមអំណាចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ។



វាងកុំអោយមានការឈ្លោះប្រកែកគ្នា ។ យើងមិនត្រូវទិតៀនអ្នកណាម្នាក់នៅមុខគេឯងទេ តែត្រូវដោះស្រាយបញ្ហាជាមួយអ្នកនោះផ្ទាល់វិញ ។ យើងធ្វើដូចនេះ ដើម្បីចៀសវាងការឈ្លោះប្រកែកគ្នា និង ការនិយាយដើមគ្នា ។



ទោះជាគ្រីស្តជនម្នាក់មិនដែលមានកំហុសអ្វីក៏ដោយ តែបើគាត់ដើរនិយាយដើមបងប្អូនគ្រីស្តជនឯទៀត នោះគាត់ធ្វើអំពើបាបធ្ងន់ធ្ងរណាស់ទៅហើយ ។ អំពើបាបខ្លះមានឥទ្ធិពលអាក្រក់តែចំពោះអ្នក ដែលបានប្រព្រឹត្តអំពើបាបនោះផ្ទាល់តែប៉ុណ្ណោះ ក៏ប៉ុន្តែ ការទិតៀនមានឥទ្ធិពលអាក្រក់ចំពោះអ្នកដទៃទៀតដែរ ។ ការទិតៀនធ្វើអោយបាត់បង់មេត្រីភាពក្នុងក្រុមជំនុំ ។

តើការប្រព្រឹត្តណាមួយអាក្រក់ជាងគេ ?

□ បង្ហាញថា មិនយល់ស្របជាមួយអ្នកណាម្នាក់ ដល់អ្នកនោះផ្ទាល់តែម្តង និង ដោយគួរសម (ឬក៏បើអ្នកនោះមានឋានៈខ្ពស់ជាង អ្នកត្រូវគោរពសូមជំរាបពីការមិនយល់ស្របរបស់អ្នក តាមរយៈអ្នកនាំពាក្យ ដែលដឹងខុសត្រូវម្នាក់) ។

□ ការនិយាយដើមអ្នកណាម្នាក់ ។

សូមជ្រើសរើសចំលើយអ្នក ដោយមើលសេចក្តីខាងក្រោមនេះ :

«មិនត្រូវដើរបរិហារកេរ្តិ៍ប្រជាជនរបស់អ្នកឡើយ ហើយក៏កុំចោទប្រកាន់អ្នកដទៃ ធ្វើអោយគេទទួលទោសប្រហារជីវិតដែរ ។ យើងជាព្រះអម្ចាស់ ។ មិនត្រូវមានចិត្តស្អប់បងប្អូនរបស់អ្នក តែត្រូវយកចិត្តទុកដាក់ស្តីបន្ទោសជនរួមជាតិរបស់អ្នក ធ្វើដូច្នេះ អ្នកនឹងមិនរួមគំនិតជាមួយអ្នកនោះ ក្នុងការប្រព្រឹត្តអំពើបាបឡើយ» ។

(លេវីវិន័យ ១៩:១៦-១៧)

ព្រះគម្ពីរហាមមិនអោយរិះគន់អ្នកដទៃពីក្រោយខ្នងទេ ។ អ្នកមិនត្រូវនិយាយពីអ្នកណាម្នាក់ក្នុងអង្គប្រជុំ ដោយមិនបាននិយាយជាមួយអ្នកនោះដោយផ្ទាល់តែពីរនាក់ ជាមុនសិននោះទេ (ម៉ាថាយ ១៨:១៥-១៨) ។ បើមិនធ្វើដូចនេះទេ នឹងមានការឈ្លោះប្រកែកគ្នា នៅក្នុងពេលប្រជុំ ។



ទីមួយ : យើងអាចយកម្ជុលចាក់ប៉ែងប៉ោងអោយផ្ទុះ តែធ្វើបែបនេះ នាំអោយប៉ែងប៉ោងបែកខ្ទេចអស់ ។ ចំពោះក្រុមជំនុំក៏ដូចគ្នាដែរ បើសិនជាបណ្តោយឱ្យមានកំហឹងផ្ទុះឡើង ក្នុងអង្គប្រជុំណាមួយ ច្បាស់ជាលែងមានការស្រុះស្រួលគ្នាក្នុងក្រុមជំនុំហើយ ។



- បើមានការសំរេចចិត្តជាឯកច្ឆន្ទ ទើបជាការប្រសើរ ។ ដើម្បីអាចមានការស្រុះស្រួលគ្នា ដោយសេចក្តីស្រឡាញ់របស់ព្រះគ្រីស្តបាន ត្រូវតែមានអ្នកខ្លះសុខចិត្តយល់ព្រមតាមគំនិតរបស់អ្នកឯទៀត ។



ច្បាប់ ទី ៤

ពួកគេនៅស្ងៀម នៅពេលដែលនរណាម្នាក់និយាយ

សូមអាន កិច្ចការ ១៥:១២ ។

គោលគំនិតសំខាន់ៗដែលដកស្រង់ពីខគម្ពីរទាំងនេះ :

- ពេលដែលអ្នកណាម្នាក់កំពុងនិយាយ សមាជិកឯទៀតមិននិយាយកាត់ទេ ។
- សមាជិកដែលចូលរួម មិនស្រែកបង្គាក់អ្នកដែលកំពុងនិយាយទេ ។ នៅពេលដែលអ្នកណាម្នាក់កំពុងនិយាយ យើងត្រូវរង់ចាំ ដោយស្ងាត់ស្ងៀម ។
- យើងត្រូវគោរពបងប្អូនគ្រីស្តជន ដែលជាសមាជិកក្រុមជំនុំរបស់យើង ទោះជាអ្នកនោះមានមតិផ្សេងពីយើងក៏ដោយ ។

បើមាននរណាម្នាក់កំពុងនិយាយ ហើយយើងចង់និយាយអ្វីមួយ :

☐ យើងរង់ចាំអោយអ្នកនោះនិយាយចប់សិន ។

☐ យើងនិយាយកាត់អ្នកនោះ ។

ច្បាប់ ទី ៥

ពួកគេទូលសូមអោយព្រះជាម្ចាស់ ដឹកនាំគេ តាមរយៈព្រះគម្ពីរ

សូមអាន កិច្ចការ ១៥:១៣-២១ ។

គោលគំនិតសំខាន់ៗ ដែលដកស្រង់ពីខគម្ពីរទាំងនេះ :

- យ៉ាកុបស្នើជូនដំណោះស្រាយដ៏ល្អមួយ ស្របតាមព្រះគម្ពីរ ។
- ដំណោះស្រាយរបស់គាត់ តម្រូវទៅតាមជំនឿរបស់ពួកគេម្នាក់ៗ ។ ពួកគេមិនបង្ខំអោយសាសន៍ដទៃ/ជនជាតិយូដាប្រកាន់តាមក្រិត្យវិន័យលោកម៉ូសេ ដើម្បីអោយបានសង្គ្រោះទេ ។ យើងបានសង្គ្រោះ ដោយសារព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ។ ប៉ុន្តែ ពួកសាវ័កបានសុំអោយសាសន៍ដទៃចៀសវាងការប្រព្រឹត្តអ្វី ដែលធ្វើអោយពួកយូដាទាស់ចិត្តខ្លាំង ។

តើយើងដោះស្រាយបញ្ហា ដោយរបៀបណា ?

☐ ដោយធ្វើតាមព្រះគម្ពីរ ។

☐ ដោយធ្វើតាមគំនិតខ្លួនផ្ទាល់ ។

ច្បាប់ ទី ៦

ពួកគេព្រមព្រៀងគ្នាជាឯកច្ឆន្ទ

សូមអាន កិច្ចការ ១៥:២២-២៧ ។ សាវ័កទាំងអស់យល់ព្រមតាមសេចក្តីស្នើរបស់លោកយ៉ាកុប ។

គោលគំនិតសំខាន់ៗដែលដកស្រង់ពីខគម្ពីរទាំងនេះ :

- ពួកគេសំរេចចិត្តព្រមព្រៀងគ្នា ដោយស្ម័គ្រចិត្ត ។ គ្មាននរណាម្នាក់ត្រូវគេបង្ខំឱ្យយល់ព្រម ខុសពីមនសិការរបស់ខ្លួនឡើយ ។
- អ្នកចូលរួមប្រជុំជាច្រើន ត្រូវឈប់ទទួចរឹងរូស ចង់ប្រកាន់យកគំនិតផ្ទាល់ខ្លួនទៀត ដើម្បីឱ្យមានការស្រុះស្រួលគ្នា ។
- អ្នកដឹកនាំណែនាំអោយគេអាចរកឃើញដំណោះស្រាយត្រឹមត្រូវបាន ។ គាត់ដឹងច្បាស់ពីពេល ដែលសមាជិកពិភាក្សាគ្នាសមល្មមហើយ ។ បន្ទាប់មក គាត់ពន្យល់អំពីដំណោះស្រាយ ដើម្បីអោយសមាជិកគ្រប់គ្នាអាចយល់បាន ។